ទិដ្ឋភាពទូទៅនៃទស្សនៈវិស័យ LBUSD ឆ្នាំ២០៣៥

# ការស្រមៃគិតឡើងវិញអំពីការអប់រំនៅ LBUSD

កាលពីរដូវស្លឹកឈើជ្រុះ ឆ្នាំ២០២២ កន្លងមកនេះ គណៈកម្មការអប់រំ និងអគ្គនាយករបស់មណ្ឌលអប់រំឡុងប៊ិច បានសម្ពោធបើកដំណើរការសហការនៅក្នុងមណ្ឌលអប់រំទាំងមូល ដើម្បីបង្កើតនូវទស្សនៈវិស័យរយៈពេលវែងមួយ អំពីវិធីដែលប្រព័ន្ធសាលារដ្ឋនឹងធ្វើការអប់រំសិស្ស តាំងពីកំណើតរហូតដល់ថ្នាក់ទី១២ និងហួសពីនោះទៀត នៅក្នុងមណ្ឌលអប់រំឡុងប៊ិចនេះ។

"ទស្សនៈវិស័យ ២០៣៥: ការអប់រំដែលស្រមៃគិតឡើងវិញនៅ LBUSD"
គឺត្រូវបានអភិវឌ្ឍឡើងតាមរយៈការងារដែលរៀបចំបង្កើតប្រកបដោយ កិច្ចសហការនៃសម្ព័ន្ធការងារដឹកនាំ—គឺមនុស្សមួយក្រុមដែលមានចំនួន ១០៣នាក់ ដែលរួមមានសិស្ស ក្រុមគ្រួសារ និងសមាជិកសហគមន៍ ព្រមទាំងបុគ្គលិកមណ្ឌលអប់រំ
ដែលត្រូវបានជ្រើសរើសដោយសារពួកគេតំណាងអោយសហគមន៍និងទស្សនៈដ៏ចំរុះ—ដោយមានការផ្តល់យោបល់
និងមតិកែលម្អពីសហគមន៍ទាំងមូលនៅឡុងប៊ិច តាមការប្រជុំចំនួន ៨២ដង និងការស្ទង់មតិចំនួន ៣ដង។ ការចូលរួមពាក់ព័ន្ធនិងកិច្ចការនេះរួមបញ្ចូលការស្រាវជ្រាវអំពីនិន្នាការក្នុងពេលអនាគត ដែលអាចនឹងជះឥទ្ធិពលលើការអប់រំ ដំណើរការក្នុងការសិក្សា (ដោយផ្ទាល់និងតាមអនឡាញ) ចំពោះសាលារៀននិងអង្គការនានាដែលបានចូលរួមរួចមកហើយក្នុងការរៀបចំការអប់រំឡើងវិញ និងលំហាត់ធ្វើការងារដែលផ្តោតលើសមធម៌ដែលបានពិចារណាចំពោះតំរូវការចាំបាច់របស់សិស្ស បុគ្គលិក ក្រុមគ្រួសារ និងសមាជិកសហគមន៍ទាំងមូល។

ទស្សនៈវិស័យសំរាប់មណ្ឌលអប់រំឡុងប៊ិច ផ្តោតលើអ្វីដែលយើងចង់អោយក្លាយជាការពិតសំរាប់អ្នករៀនចប់ទាំងអស់របស់យើង។ ការអនុវត្តការងារនេះគឺជាដំណើរការមួយដែលមានភាពឆ្លៃប្រឌិត ការសិក្សាស្រាវជ្រាវ ព្រមទាំងការអភិវឌ្ឍនិងកិច្ចសហការឥតឈប់ឈរ។ ការមានទិសដៅរួមគ្នាដូច្នោះនឹងពន្លឿនលទ្ធផលបាន ដោយផ្សារភ្ជាប់សកម្មភាពនានាទៅនឹងធនធានជាច្រើន និងដោយធ្វើការបំផុសគំនិតអោយមានកិច្ចសហការពាក់ព័ន្ធគ្នាជាច្រើន។

សូមចូលរួមធ្វើការងារនេះជាមួយពួកយើង!
ពិនិត្យមើល [www.lbschools.net/strategicplan](http://www.lbschools.net/strategicplan) សំរាប់វិធីដើម្បីចូលរួមពាក់ព័ន្ធ។

## សេចក្តីថ្លែងការអំពីទស្សនៈវិស័យ:

អ្នករៀនចប់ពីមណ្ឌលអប់រំឡុងប៊ិច គឺត្រៀមខ្លួនជាស្រេចសំរាប់អនាគត។ ពួកគេគឺអាចទុកចិត្តបាន មានសីលធម៌និងធន់ និងមានសមត្ថភាពអាចរៀនសូត្រ សហការគ្នា និងសំរបខ្លួនតាមកាលៈទេសៈដែលកំពុងប្រែប្រួលបាន។ ពួកគេបំពេញការងារយ៉ាងមានទំនុកចិត្តក្នុងសេវាកម្មនៃយុត្តិធម៌។

## ទស្សនៈវិស័យសំរាប់ឆ្នាំ ២០៣៥ រួមមានវិស័យសំខាន់ៗចំនួនបួន

រូបភាពអ្នករៀនចប់នេះ មើលឃើញលទ្ធផលវែងឆ្ងាយសំរាប់សិស្ស—សេចក្តីប្រាថ្នារបស់សហគមន៍ចំពោះអ្វីដែលអ្នករៀនចប់នឹងចេះ ក្លាយជា និងមានសមត្ថភាពអាចធ្វើបាន ដើម្បីរីកចំរើនក្នុងជីវិតនិងវិជ្ជាជីវៈរបស់ពួកគេបាន។

រូបភាពមនុស្សធំរៀបរាប់អំពីអ្វីដែលមនុស្សធំទាំងអស់កំពុងធ្វើការនៅមណ្ឌលសាលា ត្រូវការចេះ ក្លាយជា និងមានសមត្ថភាពអាចធ្វើបាន ដើម្បីជួយដល់ដំណើរការសិក្សារបស់សិស្សម្នាក់ៗ អោយឆ្ពោះទៅសំរេចយករូបភាពអ្នករៀនចប់បាន។

រូបភាពប្រព័ន្ធផ្តោតលើការបង្កើតអោយមានលក្ខ័ណនានាដែលធ្វើអោយសិស្សនិងមនុស្សធំនៅ LBUSD រីកចំរើននិងលូតលាស់ ដោយមានការដឹកនាំតាមគុណតម្លៃសំខាន់ៗជាច្រើន។

គុណតម្លៃទាំងនេះបញ្ជាក់អំពីគោលការណ៍ដែលដឹកនាំសកម្មភាពនានារបស់មណ្ឌលអប់រំ ក្នុងការអនុវត្តនូវទស្សនៈវិស័យនេះអោយបាន។

តួនាទីដ៏សំខាន់របស់ប្រព័ន្ធសាលារៀននីមួយៗ គឺទាក់ទាញសិស្សអោយចូលរួមនៅសាលានិងក្នុងពេលនេះតែម្តង ខណៈដែលត្រៀមលក្ខណៈពួកគេអោយរីកចំរើនក្នុងជីវិតនិងវិជ្ជាជីវៈរបស់ពួកគេបាន។ ទោះជាយ៉ាងនេះក្តី ភារៈកិច្ចនៃការត្រៀមលក្ខណៈមនុស្សក្មេងៗរបស់យើងសំរាប់អនាគត គឺមិនមែនជាកិច្ចការរបស់ពួកយើងតែឯកឯងប៉ុណ្ណោះទេ។ ទស្សនៈវិស័យសំរាប់សិស្សរបស់យើងនេះ គឺនឹងមិនអាចសំរេចទៅបានទេ លុះត្រាតែយើងធ្វើការនៅក្នុងសហគមន៍រួមគ្នាជាផ្លូងមួយបាន។ ទស្សនៈវិស័យនេះ គឺជាការអំពាវនាវអោយមានសកម្មភាពដ៏អង់អាចមួយ ដើម្បីជួយដល់សិស្សរបស់មណ្ឌលអប់រំឡុងប៊ិចបាន។ ទស្សនៈវិស័យនេះត្រូវបានចងក្រងសរសេរនៅក្នុងពេលបច្ចុបន្ន គឺហាក់ដូចជាត្រូវបានអនុវត្តរួចរាល់ហើយអញ្ចឹង ដើម្បីផ្តល់នូវស្មារតីយល់ឃើញអំពីថាតើអនាគតអាចនឹងមានរូបរាងយ៉ាងណានោះ។

# គុណតម្លៃសំខាន់ៗ

គុណតម្លៃសំខាន់ៗគឺជាជំនឿដ៏ជាប់លាប់ដែលដឹកនាំសកម្មភាពនានារបស់អង្គការមួយក្នុងរយៈពេលយូរ។ សេចក្តីថ្លែងការតទៅនេះត្រូវបានបង្កើតឡើងតាមរយៈកិច្ចការរៀបទស្សនៈវិស័យនេះ និងប្រចាប់បញ្ចូលគ្នានូវគុណតម្លៃមុនៗរបស់មណ្ឌលអប់រំជាមួយនឹងគោលគំនិតសំខាន់ៗដែលផ្សារភ្ជាប់ទៅនឹងទស្សនៈវិស័យនេះ។ ខណៈដែលគុណតម្លៃសំខាន់ៗគឺជាមូលដ្ឋានគ្រឹះយ៉ាងណាក្តី ក៏អង្គការនានាត្រូវការស្រាយបំភ្លឺអំពីផ្នត់គំនិតនិងមធ្យោបាយធ្វើការដែលផ្សារភ្ជាប់ជាមួយអនាគតដែលប្រាថ្នាចង់ផងដែរ នៅពេលដែលបង្កើតអោយមានការផ្លាស់ប្តូរប្រព័ន្ធតាមបែបណាមួយនោះ។ ការផ្សារភ្ជាប់គុណតម្លៃនានាទៅនឹងទស្សនៈវិស័យ គឺធ្វើអោយសីលធម៌របស់មណ្ឌលអប់រំមានភាពច្បាស់លាស់និងធានាអោយមានការទំនាក់ទំនងគ្នាបាន។

- ការផ្តោតលើតំរូវការចាំបាច់និងមតិរបស់សិស្ស
- ការចូលរួមនិងកិច្ចសហការសហគមន៍ដែលពិតប្រាកដ
- វប្បធម៌នៃការកែឆ្នៃនិងភាពឆ្នៃប្រឌិត
- ភាពចំរុះនិងការដាក់បញ្ចូលទាំងអស់គ្នា
- បរិស្ថានដែលជំរុញអោយមានភ្ជាប់ទំនាក់ទំនងគ្នា ការគោរពគ្នា និងសុវត្ថិភាព
- សមធម៌និងយុត្តិធម៌សង្គម
- ឧត្តមភាពនិងការទទួលខុសត្រូវតាមរយៈការអភិវឌ្ឍឥតឈប់ឈរ
- ការជំរុញអោយមានការសប្បាយនិងការប្តេជ្ញាចិត្ត
- ការដឹកនាំដែលថ្លៃថ្នូនិងទទួលខុសត្រូវ

# រូបភាពអ្នករៀនចប់

រូបភាពអ្នករៀនចប់មើលឃើញលទ្ធផលដ៏វែងឆ្ងាយសំរាប់សិស្ស—សេចក្តីប្រាថ្នារបស់សហគមន៍សំរាប់អ្វីដែលអ្នករៀនចប់នឹងចេះ ក្លាយជា និងមានសមត្ថភាពអាចធ្វើបាន ដើម្បីរីកចំរើននៅក្នុងជីវិតនិងវិជ្ជាជីវៈរបស់ពួកគេបាន។

ការប្តេជ្ញាចិត្តរបស់ពួកយើង គឺជួយជ្រោមជ្រែងដល់សិស្សគ្រប់រូបអោយសំរេចបាននូវធាតុផ្សំនៃរូបភាពអ្នករៀនចប់អោយបានល្អបំផុតទៅតាមលទ្ធភាពរបស់ពួកគេ។ សេចក្តីប្រាថ្នានេះគឺធំធេងណាស់ ដើម្បីធ្វើកត្តាលីករចំពោះការកែប្រែប្រព័ន្ធជាច្រើនដែលត្រូវការចាំបាច់ ដើម្បីជួយជ្រោមជ្រែងដល់លទ្ធផលសិក្សារបស់សិស្ស និងដឹកនាំសកម្មភាពនិងសេចក្តីសំរេចនានារបស់មនុស្សធំបាន។ រូបភាពអ្នករៀនចប់ដូចតទៅនេះ ដែលបានបង្កើតចេញពីកិច្ចការនៃសម្ព័ន្ធដឹកនាំនិងសហគមន៍ដ៏ទូលំទូលាយមួយនេះ គឺនឹងត្រៀមលក្ខណៈសិស្សម្នាក់ៗសំរាប់ជីវិតបានហួសពីពេលក្រោយរៀនចប់វិទ្យាល័យទៅទៀត ដែលនឹងជួយពួកគេអោយរីកចំរើនបាននៅក្នុងពិភពលោកមួយដែលមានការផ្លាស់ប្តូរឥតឈប់ឈរ។

## មនុស្សធំដែលត្រៀមខ្លួនជាស្រេចដើម្បីអនាគត

*សិស្សទាំងអស់គឺត្រូវបានត្រៀមខ្លួនជាស្រេចដើម្បីអនាគតរបស់ពួកគេ ដោយមានបំណិនជីវិតសំខាន់ៗ ត្រូវតភ្ជាប់ទៅនឹងបណ្តាញសម្ព័ន្ធមិត្ត ហើយមានទិសដៅនិងផែនការមួយសំរាប់រយៈពេលមួយជីវិត ក្រោយពីពេលបញ្ចប់ការសិក្សានៅវិទ្យាល័យរួច។*

## អ្នកដឹកនាំដែលមានសមធម៌និងការដាក់បញ្ចូលទាំងអស់គ្នា

*សិស្សមើលឃើញភាពចម្រុះថាជាធនធានចំពោះសហគមន៍ទាំងមូលរបស់យើង យល់អំពីឫសគល់ប្រវត្តិនៃភាពលំអៀងចំពោះពូជសាសន៍និងវប្បធម៌ដែលបានបង្កអោយមានការអនុវត្តនូវការគៀបសង្កត់នៅតាមស្ថាប័ន ហើយចេះអំពីវិធីប្រព្រឹត្តតាមមធ្យោបាយដែលលើកកម្ពស់សមធម៌និងការដាក់បញ្ចូលទាំងអស់គ្នាបាន។*

## ជាមនុស្សដែលអាចទុកចិត្តបាន និងគួរអោយគោរព

*សិស្សគឺទទួលខុសត្រូវ អាចទុកចិត្តបាន ចេះយល់ចិត្ត និងប្រណិបត្តបាននូវអាកប្បកិរិយាដែលគួរអោយគោរពចំពោះអ្នកដទៃនិងបរិស្ថានរបស់យើង ទាំងជាមួយមនុស្សផ្ទាល់ និងតាមប្រព័ន្ធឌីជីថល។*

## អ្នកតស៊ូដោយខ្លួនឯង ដែលធន់ ចេះគិតគូរ និងរីកចំរើនបាន

*សិស្សបញ្ចេញអោយឃើញនូវភាពជឿជាក់លើខ្លួនឯង អំពីរបៀបដែលគេទទួលស្គាល់នូវអត្តសញ្ញាណផ្ទាល់ខ្លួន និងរបៀបដែលពួកគេតស៊ូមតិដើម្បីតំរូវការចាំបាច់របស់ពួកគេបាន។ ពួកគេគឺធន់ទាំងផ្លូវចិត្តនិងផ្លូវកាយ ចេះរបៀបគ្រប់គ្រងភាពតានតឹងផ្លូវចិត្ត ហើយធ្វើការឆ្ពោះទៅរករបៀបរស់នៅដែលមានតុល្យភាពមួយបាន។*

## បញ្ញាវ័ន្តដែលអាចសំរបខ្លួនបានអស់មួយជីវិត

*សិស្សមើលឃើញការរៀនសូត្រថាជាការខិតខំប្រឹងប្រែងអស់មួយជីវិត ដែលធ្វើអោយពួកគេអាចបន្តស្វែងរកចំណង់ចំណូលចិត្តនិងផលប្រយោជន៍របស់ពួកគេបាន។ ពួកគេចេះរបៀបប្រើប្រាស់ចំណេះដឹងនៃការសិក្សាមូលដ្ឋានគ្រឹះ ដែលច្របាច់បញ្ចូលគ្នានៅទូទាំងគ្រប់វិស័យទាំងអស់ ដើម្បីអភិវឌ្ឍអោយមានការយល់ដឹងថ្មីៗបាន។*

## អ្នកដោះស្រាយបញ្ហាដែលមានសីលធម៌

*សិស្សចេះរបៀបប្រើប្រាស់វិធីសាស្ត្រក្នុងការគិតគូរ ការស្រាវជ្រាវ និងការដោះស្រាយបញ្ហាដ៏ចំរុះ ដើម្បីបង្កើតអោយមានការដោះស្រាយបញ្ហាប្រកបដោយភាពឆ្នៃប្រឌិត ដែលមានចេតនាឆ្លើយតបចំពោះតំរូវការចាំបាច់របស់មនុស្សម្នាដែលត្រូវការដំណោះស្រាយទាំងនេះបាន។*

អ្នកមើលខុសត្រូវនិងអ្នកទំនាក់ទំនងសាកលដែលមានព័ត៌មានគ្រប់គ្រាន់

*សិស្សបង្ហាញថាមានសមត្ថភាពសំខាន់ៗដែលត្រូវការចាំបាច់ ដើម្បីចូលរួមយ៉ាងមានផលិតភាពក្នុងពិភពលោកទាំងមូលដែលផ្សារភ្ជាប់គ្នារបស់យើង និងធ្វើសកម្មភាពចំពោះបញ្ហាដែលមានសារៈសំខាន់នៅលើសាកលលោកនិងនៅមូលដ្ឋានបាន។*

អ្នកសហការដែលពឹងអាស្រ័យគ្នាទៅវិញទៅមក

*សិស្សអោយតម្លៃចំពោះការសហការគ្នាក្នុងក្រុមការងារចំរុះ និងចេះរបៀបប្រើទេពកោសល្យរួមនៃសមាជិកក្រុមការងាររបស់ពួកគេ ដើម្បីបង្កើនផលិតភាពនិងសំរេចលទ្ធផលបាន។*

# រូបភាពមនុស្សធំ

សមិទ្ធិផលដែលមានជោគជ័យដ៏ច្រើនលើសលប់នៃរូបភាពអ្នករៀនចប់គឺមិនអាចធ្វើទៅបានទេ លុះត្រាតែមានសហគមន៍មនុស្សធំដែលចេះជ្រោមជ្រែងគ្នានិងមានគោលដៅតែមួយ រួមគ្នាធ្វើការជាធ្លុងមួយសិនទេនោះ។

រូបភាពមនុស្សធំដែលបង្កើតចេញពីការងារនៃសម្ព័ន្ធដឹកនាំនិងសហគមន៍ដ៏ទូលំទូលាយនេះ គឺអនុវត្តចំពោះមនុស្សធំទាំងអស់ដែលធ្វើការក្នុងមណ្ឌលអប់រំនេះ។ ក្នុងនោះ គឺការស្រាយបំភ្លឺអំពីគុណភាពដែលជួយមនុស្សធំ ដើម្បីជួយជ្រោមជ្រែងដល់ដំណើរសិក្សារបស់សិស្សគ្រប់រូបអោយឈានឆ្ពោះសំរេចនូវរូបភាពអ្នករៀនចប់បាន។

ជើងឯកសំរាប់សិស្ស

*មនុស្សធំជួយទ្រទ្រង់និងជំរុញលើកទឹកចិត្តសិស្សចំពោះគោលដៅរបស់ពួកគេ ពង្រឹងសមត្ថភាពពួកគេអោយហ៊ានសាកល្បងធ្វើការប្រថុយប្រថានសមហេតុផល និងលូតលាស់បាន។*

ជាភ្នាក់ងារផ្លាស់ប្តូរដែលផ្តោតលើសមធម៌

*មនុស្សធំទ្រទ្រង់អោយមានភាពចំរុះ សមធម៌ និងការដាក់បញ្ចូលទាំងអស់គ្នា ដោយធ្វើជាគំរូនៃការយល់ដឹងអំពីវប្បធម៌ និងចូលរួមក្នុងការឆ្លុះបញ្ចាំងលើខ្លួនឯងអោយបានយ៉ាងជាប់លាប់ឥតឈប់ឈរ។*

អ្នកប្រកបវិជ្ជាជីវៈដែលល្អនិងធន់ទ្រាំបាន

*មនុស្សធំគឺឆ្លុះបញ្ចាំងលើខ្លួនឯង មានភាពជឿជាក់ និងស្រឡាញ់ចូលចិត្តការងាររបស់ខ្លួន។ ពួកគេដឹងអំពីសុខភាពផ្លូវចិត្ត ដូច្នេះហើយពួកគេអាចថែទាំខ្លួនឯងនិងអ្នកដទៃអោយល្អបាន។*

អ្នករៀនសូត្រអស់មួយជីវិតដែលចេះសំរបនិងឆ្លុះបញ្ចាំងលើខ្លួនឯង

*មនុស្សធំគឺមានចិត្តទូលាយ ចង់ដឹងចង់ឃើញ និងប្តេជ្ញាចិត្តចំពោះការរៀនសូត្រឥតឈប់ឈរ ដែលជួយដល់ការអភិវឌ្ឍខ្លួនជាអ្នកប្រកបវិជ្ជាជីវៈ និងពង្រឹងសមត្ថភាពរបស់ខ្លួន ដើម្បីសំរបខ្លួននឹងពិភពលោកមួយដែលកំពុងមានការផ្លាស់ប្តូរបាន។*

អ្នកទំនាក់ទំនងដែលចេះយល់ចិត្ត

*មនុស្សធំប្រាស្រ័យទាក់ទងនៅទូទាំងវប្បធម៌នានាបានយ៉ាងច្បាស់លាស់ដោយបើកចំហរនិងមានទឹកចិត្តស្មោះត្រង់ តាមរបៀបដែលបង្ហាញអោយឃើញការយកចិត្តទុកដាក់និងការខ្វល់ខ្វាយចំពោះសិស្ស ក្រុមគ្រួសារ និងបុគ្គលិកបាន។*

ពង្រឹងសមត្ថភាពរបស់អ្នកសំរបសំរួលការរៀនសូត្រ

*មនុស្សធំផ្តល់អោយមានបទពិសោធន៍រៀនសូត្រដែលពាក់ព័ន្ធគ្នានិងមានការចូលរួម ដើម្បីជួយទ្រទ្រង់ដល់តំរូវការចាំបាច់របស់អ្នករៀនសូត្រ (ទាំងសិស្សនិងមនុស្សធំ) ស្ថាបនាបន្ថែមទៀតលើចំណុចខ្លាំងរបស់ខ្លួន បញ្ជាក់បង្ហាញនូវអត្តសញ្ញាណរបស់ខ្លួន និងជំរុញអោយមានការលូតលាស់ផ្ទាល់ខ្លួនបាន។*

អ្នកគិតគូរដែលចេះឆ្លៃប្រឌិតនិងពិចារណា

*មនុស្សធំគឺអាចឆ្លុះបញ្ចាំងលើខ្លួនឯងបាន ជាអ្នកគិតគូរប្រកបដោយភាពកែឆ្នៃនិងផ្តោតលើការដោះស្រាយបញ្ហា ដែលអាចគិតគូរពិចារណាយ៉ាងមានភាពឆ្លៃប្រឌិត ដើម្បីដោះស្រាយបញ្ហាបាន។*

អ្នកដឹកនាំដែលគិតគូរពីសហគមន៍និងចេះសហការគ្នា

*មនុស្សធំបង្កើតនូវទំនាក់ទំនងដ៏រឹងមាំជាមួយមិត្តភក្តិនិងសហគមន៍ទាំងមូល។ ពួកគេសហការគ្នាទាំងនៅតាមមូលដ្ឋាននិងនៅលើសាកលលោក ដើម្បីធ្វើកត្តាលីករ អោយមានការផ្លាស់ប្តូរនិងសំរេចគោលដៅជារួមបាន។*

# រូបភាពប្រព័ន្ធ

រូបភាពប្រព័ន្ធរៀបរាប់អំពីការផ្លាស់ប្តូរដែលត្រូវការចាំបាច់នៅក្នុងមណ្ឌលសាលាទាំងមូល ដើម្បីបង្កើតអោយមានលក្ខ័ណ្ឌដែលពង្រឹងសមត្ថភាពមនុស្សធំអោយសំរេចបាននូវរូបភាពមនុស្សធំម្នាក់ និងជួយទ្រទ្រង់សិស្សក្នុងការសំរេចនូវរូបភាពអ្នករៀនចប់ម្នាក់អោយបាន។ កិច្ចការនេះនឹងជួយយើងអោយធានាបានថា សិស្សគ្រប់រូបគឺត្រៀមខ្លួនជាស្រេចដើម្បីអនាគត និងត្រៀមលក្ខណៈដើម្បីរីកចំរើនក្នុងជីវិតនិងវិជ្ជាជីវៈបាន នៅពេលដែលពួកគេបញ្ចប់ការសិក្សាពី LBUSD។

នេះគឺជាទស្សនៈវិស័យក្នុងរយៈពេលវែង ហើយការផ្លាស់ប្តូរទាំងនេះនឹងមិនកើតឡើងក្នុងពេលតែមួយបានទេ។ រូបភាពនេះ ដែលបង្កើតចេញពីការងារនៃសម្ព័ន្ធដឹកនាំនិងសហគមន៍ដ៏ទូលំទូលាយនេះ គឺនឹងប្រើនៅក្នុងផែនការយុទ្ធសាស្ត្រនានា ដែលនឹងកំណត់ថាតើយើងត្រូវធ្វើអ្វីខ្លះ និងតាមលំដាក់លំដោយបែបណា ដើម្បីអោយយើងអាចដឹកនាំមណ្ឌលអប់រំរបស់យើងប្រកបដោយភាពជោគជ័យ និងជួយទ្រទ្រង់ដល់សមិទ្ធិផលសិក្សារបស់សិស្សបាន។

ប្រព័ន្ធដែលមានសមធម៌និងផ្តោតលើឧត្តមភាពសំរាប់ទាំងអស់គ្នា

*LBUSD គឺជាប្រព័ន្ធអប់រំមួយដែលមានសមធម៌ៈ យើងទទួលស្គាល់ថាមានអំពើអាក្រក់ ហើយប្រើការអនុវត្ត[1] ដែលមានការស្តារឡើងវិញដើម្បីធ្វើការផ្សះផ្សារគ្នាបាន។ យើងផ្អែកការបែងចែកធនធានរបស់យើងទៅលើតំរូវការចាំបាច់របស់សិស្ស។ យើងប្រើផ្នត់គំនិតនិងការអនុវត្តដែលអាចជួយអោយមានសេរីភាព ដើម្បីស្រមៃគិតឡើងវិញអំពីដំណើរការនិងរចនាសម្ព័ន្ធដែលមានសមធម៌ ដើម្បីផ្តល់អំណោយផលដល់សិស្សអោយសំរេចនូវសក្តានុពលដ៏ពេញលេញរបស់ខ្លួនបាន។*

ការរៀនសូត្រដែលអាចបត់បែនបាននិងមានគុណភាពខ្ពស់ ដោយមានការអនុវត្តតាមពិភពលោកជាក់ស្តែង

*សិស្ស LBUSD គ្រប់រូប គឺត្រូវបានជួយទ្រទ្រង់អោយអភិវឌ្ឍស្មារតីនៃការទទួលខុសត្រូវរបស់ខ្លួន និងសំរេចសក្តានុពលដ៏ពេញលេញរបស់ខ្លួនបានតាមរយៈបទពិសោធន៍សិក្សាដែលជួយអោយចេះបត់បែនបាន អោយចេះមើលឆ្ពោះទៅមុខ ដោយមានការអនុវត្តតាមពិភពលោកជាក់ស្តែង។*

---

[1] ការអនុវត្តការស្តារយុត្តិធម៌ឡើងវិញ គឺជាមធ្យោបាយមួយនៃការធ្វើការងារជាមួយជម្លោះ ដែលដាក់ការផ្តោតចិត្តទុកដាក់លើការផ្សះផ្សារចំពោះអំពើអាក្រក់ដែលបានប្រព្រឹត្តរួចមកហើយ។ វាគឺជាមធ្យោបាយមួយឆ្ពោះទៅរកដំណោះស្រាយដែលរួមបញ្ចូលគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

## មណ្ឌលអប់រំដែលបើកទូលាយៈ ការសហការគ្នារវាងក្រុមគ្រួសារ សហគមន៍ និងទីក្រុង

*LBUSD ប្តេជ្ញាចិត្តដើម្បីធ្វើការជាដៃគូគ្នាជាមួយក្រុមគ្រួសាររបស់យើង សហគមន៍របស់យើង និងអភិបាលកិច្ចទីក្រុងរបស់យើង ហើយយើងអភិវឌ្ឍអោយមានប្រព័ន្ធនិងរចនាសម្ព័ន្ធចាំបាច់នានា ដើម្បីបង្កើតអោយមានទំនុកចិត្ត ស្តាប់ដោយយកចិត្តទុកដាក់ បង្កើតគោលដៅរួម ព្រមទាំងសហការគ្នាដើម្បីសំរេចអ្វីទាំងនេះអោយបាន។*

## ភាពប្រទាក់គ្នានិងសមត្ថភាពលើសាកលលោក

*LBUSD អោយតម្លៃចំពោះភាពចំរុះនៃវប្បធម៌ដ៏សម្បូរបែបនិងភាពប្រទាក់គ្នាលើសាកលលោក។  យើងជួយទ្រទ្រង់សិស្សនិងបុគ្គលិករបស់យើងក្នុងការអភិវឌ្ឍអោយមានការយល់ដឹង និងសេចក្តីអំណរ តាមរយៈជំនួយគាំទ្រអោយមានកម្មវិធីពហុភាសានិយម និងកម្មវិធីអន្តរជាតិ។*

## វប្បធម៌មួយនៃការដាក់បញ្ចូលទាំងអស់គ្នា សុខុមាលភាព និងការបញ្ជាក់អះអាង

*LBUSD មានចេតនាអភិវឌ្ឍអោយមានវប្បធម៌ដែលជួយអោយមានការបញ្ជាក់អះអាងនិងផ្អែកលើធនធានដែលមានស្រាប់ ដែលសិស្ស សមាជិកក្រុមគ្រួសារ បុគ្គលិក និងសមាជិកសហគមន៍គ្រប់រូប មានអារម្មណ៍ថាមានភាពរាក់ទាក់ស្វាគមន៍និងចូលជំនុំចំណោមគ្នាបាន។*

## វប្បធម៌មួយដែលផ្តោតលើសមធម៌ ភាពកែឆ្នៃ និងភាពឆ្នៃប្រឌិត

*ការអនុវត្តដែលមានភាពកែឆ្នៃនៅទូទាំងប្រព័ន្ធអប់រំរបស់ LBUSD គឺបង្កើតនូវស្មារតីទទួលខុសត្រូវរបស់សិស្សនិងបុគ្គលិក ដើម្បីសហការគ្នាក្នុងក្រុមដ៏ចំរុះនានា គិតគូរដោយមានភាពឆ្នៃប្រឌិតអំពីបញ្ហាព្រឈម និងរៀនសូត្រឆ្ពោះទៅមុខបាន ដោយធ្វើគំរូ[2] ជាដំណោះស្រាយនានា។*

## សេវាដ្ឋានអាគារដែលផ្តោតលើអនាគត និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា

*យើងមានភាពសកម្មក្នុងការរៀបចំផែនការ រចនាបង្កើត និងទ្រទ្រង់ថែរក្សាសេវាដ្ឋានអាគាររបស់យើង និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យារបស់យើង។ យើងរៀបចំផែនការត្រៀមសំរាប់ភាពធន់នឹងធាតុអាកាស ដើម្បីយើងអាចបង្កើតអោយមានបរិយាកាសដែលត្រៀមជាស្រេចដើម្បីអនាគត ទាំងការចូលរួមដោយផ្ទាល់និងចូលរួមតាមអនឡាញ នៅខណៈពេលដែលយើងចាត់ចែងលើថ្លៃចំណាយ។*

## ការអនុវត្តនៃមនុស្សធំដែលមានការផ្លាស់ប្តូរនិងការដឹកនាំ

*ការងាររបស់មនុស្សធំគ្រប់រូបនៅ LBUSD គឺសំខាន់ណាស់ចំពោះសមិទ្ធិផលសិក្សារបស់សិស្ស។  មនុស្សធំទាំងអស់អភិវឌ្ឍអោយមានការអនុវត្តដែលឈានមុខគេ ដែលផ្សារភ្ជាប់ទៅនឹងរូបភាពមនុស្សធំ វិវត្តន៍ខ្លួនតាមរយៈការអភិវឌ្ឍឥតឈប់ឈរ និងធ្វើការផ្លាស់ប្តូរបទពិសោធន៍រៀនសូត្រនិងកិច្ចការអោយបានល្អសំរាប់សិស្សនិងមិត្តរួមការងារ។*

[ចំណងជើងសំរាប់ឌីយ៉ាក្រាម] រូបភាពនានារបស់ LBUSD

[2] កាធ្វើជាគំរូ គឺសំដៅទៅលើដំណាក់កាលដែលយើងបង្កើតអោយមានជាគំរូងាយៗនៃការដោះស្រាយបញ្ហាសំខាន់ណាមួយ ប្រើវិធានការតូចបំផុតតាមដែលយើងអាចធ្វើបាន ដើម្បីរៀនសូត្រអំពីបញ្ហាឬដំណោះស្រាយនោះបាន។  បន្ទាប់មកគឺយើងសាកល្បងប្រើគំរូនោះ ហើយបង្កើតនូវច្បាប់កែប្រែជាបន្តទៀត ដោយផ្អែកលើការរៀនសូត្ររបស់យើង។